long beach unified school district

Long Beach Unified School District
1515 Hughes Way
Long Beach, CA 90810
(562) 997-8000

ជំរាបជូនមាតាបិតា/អ្នកគ្រប់គ្រងនៃសិស្សៈ

រៀងរាល់ឆ្នាំ សិស្សថ្នាក់ទី បី ទៅ ទី ប្រាំបី និង សិស្សកំរិតថ្នាក់សាលា ហាយស្គូល ចូលរួមការប្រឡង តែស្ត មួយ ហៅ California Assessment of Student Performance and Progress (CAASPP) សំរាប់ស្ទង់វាស់សមត្ថភាពផ្នែកសិក្សា ។

នៅរដូវផ្ការីកនេះ សិស្សរបស់អ្នកនឹងប្រឡង តែស្ត ដូចតទៅ ស្របតាមកំរិតថ្នាក់របស់គេៈ

- Smarter Balanced Summative Assessments សំរាប់ចុងឆ្នាំសិក្សា ផ្នែកភាសា អង់គ្លេស និង គណិតស្រាស្ត (កំរិតថ្នាក់ទី 3 – 8 និង 11)
- California Science Test (CAST) - ការប្រឡងផ្នែកវិទ្យាសាស្ត្រ (កំរិតថ្នាក់ទី 5, 8 និង 12)

ការប្រឡង Smarter Balanced សំរាប់ចុងឆ្នាំសិក្សា និង CAST គឺឆ្លើយសំនួរតាមរយៈ អនឡាញ ដែលស្ទង់វាស់ចំណេះអ្វី ដែលសិស្សរបស់អ្នកយល់ដឹង និង អាចធ្វើទៅបាន ។ នៅក្នុងសំនួរ គឺមានជាច្រើនចំណែក ដែលផ្តល់ឱកាសសំរាប់សិស្សធ្វើការឆ្លើយឆ្លងជាមួយ ។ លទ្ធផលនឹងជួយបង្ហាញអំពីភាពខុសគ្នារវាងចំណេះតាំងពីសិស្សរបស់អ្នកបានចូលរៀនមក ដើម្បីងាយស្វែងរកជំនួយសំរាប់ជួយគេទទួលជោគជ័យនៅក្នុងសាលារៀន ។

លទ្ធផលពីការប្រឡង CAASPP នឹងប្រើរួមជាមួយលទ្ធផលផ្សេងៗទៀត ដែលមាន ដើម្បីរៀបចំត្រឹមត្រូវជាកម្មវិធី មេរៀន និង សាលារៀនសំរាប់សិស្សរបស់អ្នក ។ ក្នុងនាមជាមាតាបិតា ឬ អ្នកគ្រប់គ្រងនៃសិស្ស គឺរៀងរាល់ឆ្នាំ អ្នកមានសិទ្ធិមិនព្រមទទួលអោយសិស្សរបស់អ្នកចូលរួមការប្រឡង CAASPP បាន ។ បើអ្នកមានបំណងមិនព្រមទទួលអោយសិស្សរបស់អ្នកចូលរួមការប្រឡង គឺសូមមេត្តាសរសេរជាសំបុត្របង្ហាញអំពីការស្នើសុំរបស់អ្នក ដើម្បីអោយសាលារៀននៃសិស្សរបស់អ្នកអាចរក្សាទុកបានជាសំណុំរឿងនៅក្នុងក្រសួងអប់រំ ឌីស្ទ្រីគ ។ [ច្បាប់សិក្សា 60615]

អ្នកមានមុខងារសំខាន់មួយចំណែកជាមួយការសិក្សានៃសិស្សរបស់អ្នក ។ ដើម្បីជួយសិស្សរបស់អ្នកប្រុងប្រៀបសំរាប់ការប្រឡង គឺអ្នកអាចៈ

- ជជែកអំពីការប្រឡងជាមួយសិស្សរបស់អ្នក ។ ជួយគេកុំអោយមានការភិតភ័យ ។
- និយាយទៅកាន់សិស្សរបស់អ្នកថា រូបអ្នកផ្ទាល់ និង គ្រូបង្រៀនរបស់គេមានសេចក្តីសង្ឃឹមខ្ពស់មកលើការប្រឡង និង អ្នកទាំង ពីរ នឹងតាមជួយគ្រប់ពេលវេលា ។
- ហាត់ឆ្លើយសំនួរជាមួយសិស្សរបស់អ្នក ។
- រៀបចំពេលវេលាសំរាប់សិស្សរបស់អ្នកចូលគេងគ្រប់គ្រាន់ និង ទទួលអាហារពេលព្រឹកគ្រប់គ្រាន់ មុនដល់ពេលត្រូវប្រឡង ។

ដើម្បីរៀនចំណាំកាន់តែច្បាស់អំពីការប្រឡង Smarter Balanced Summative Assessments ឬ CAST សូមបើកមើលនៅតាមក្បួនណែនាំសំរាប់មាតាបិតានៃក្រសួងអប់រំប្រចាំរដ្ឋ កាលីហ្វ័រញ៉ា ដែលមាននៅក្នុងគេហទំព័រ https://www.cde.ca.gov/ta/tg/ca/parentguidetounderstand.asp ។

អ្នកក៏អាចបើកមើលបានដែរអំពីគំរូសំនួរសំរាប់ហាត់ឆ្លើយជាមួយការប្រឡង CAASPP ដែលមាននៅក្នុងគេហទំព័រ http://www.caaspp.org/practice-and-training/index.html ។

សំរាប់ពត៌មានបន្ថែមអំពី ថ្ងៃ/ខែ និង ពេលវេលា ដែលសិស្សរបស់អ្នកត្រូវប្រឡងនៅតាមមុខវិជ្ជានិមួយៗ សូមមេត្តាទាក់ទងសាលារៀននៃសិស្សរបស់អ្នក ។

ដោយសេចក្តីគោរព

នាយកសាលារៀន